រស្មីកម្ពុជា ផ្សាយថ្ងៃសៅរ៍ ទី៤ សីហា ២០០៧

Raksmey Kampuchea News: KKC demands Mr. Tim Sakhorn repatriated to Cambodia. Saturday August 4, 2007

# សហគមន៍ខ្មែរកម្ពុជាក្រោមទាមទារឱ្យបញ្ជូនលោកទឹម-សាខនមកកម្ពុជាវិញ

**ភ្នំពេញ:** សហគមន៍ខ្មែរកម្ពុជាក្រោមបានទាមទារឱ្យបញ្ជូនលោកទឹម សាខន មកកម្ពុជាវិញបន្ទាប់ពីទទួលបានព័ត៌មានពីវិទ្យុផ្សាយសំឡេងវៀត-ណាមនិងគេហទំព័រវៀតណាមកាន់ថ្មីដែលបានផ្សាយកាលពីថ្ងៃទី២ខែសីហាឆ្នាំ២០០៧ថា លោកទឹម សាខន អតីតព្រះចៅអធិការវត្តភ្នំដិនខាងជើង ស្រុក

តទៅទំព័រ ក២

តមកពីទំព័រ ក១

## សហគមន៍ខ្មែរ...

គិរីវង់ ខេត្តតាកែវ ត្រូវបានអាជ្ញាធរវៀតណាមឃុំឃាំងក្នុងពន្ធនាគារនៃប្រទេសវៀតណាម ដោយចោទប្រកាន់ពីបទឆ្លងដែនខុសច្បាប់និងបំផ្លិចបំផ្លាញគោលនយោបាយសាមគ្គីភាពកម្ពុជា-វៀតណាម ។

លោក ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានអំពាវនាវនៅក្នុងសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី២ខែសីហាឆ្នាំ២០០៧ ស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើអន្តរាគមន៍គ្រប់មធ្យោបាយការទូត ដើម្បីនាំយកលោកទឹម-សាខន ត្រឡប់មកកម្ពុជាវិញនិងបើកការស៊ើបអង្កេតយ៉ាងលម្អិតមួយចំពោះករណីចាប់ខ្លួនលោកទឹម សាខន ទៅឱ្យអាជ្ញាធរវៀតណាម រួមទាំងលិខិតស្នើសុំរបស់លោកទឹម សាខននោះផង ដើម្បីរកមុខរកជនល្មើសរំលោភរដ្ឋធម្មនុញ្ញយកមកផ្តន្ទាទោសតាមផ្លូវច្បាប់។ សេចក្តីថ្លែងការណ៍ក៏បានអំពាវនាវផងដែរដល់រាជរដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ និងបណ្តាស្ថានទូតនានាប្រចាំនៅកម្ពុជាជួយឃ្លាំមើលនិងការពារសុវត្ថិភាពដល់លោកទឹម សាខន ដែលកំពុងជាប់ពន្ធនាគារនៅប្រទេសវៀតណាម ។ សេចក្តីថ្លែងការណ៍បានអះអាងថា ការចោទប្រកាន់របស់អាជ្ញាធរវៀតណាមដែលថាលោកទឹម សាខន ឆ្លងដែនចូលប្រទេសវៀតណាមដោយខុសច្បាប់នោះ អាចបញ្ជាក់បានថា លោកទឹម សាខន ជាពលរដ្ឋខ្មែរយ៉ាងពិតប្រាកដ ។

គួររំលឹកថា កាលពីថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០០៧ លោកទឹម សាខន បានបាត់ខ្លួនដោយអាថ៌កំបាំង បន្ទាប់ពីការចាប់ផ្សឹកដោយមន្ត្រីសង្ឃជាន់ខ្ពស់កម្ពុជា ។

លោកខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានប្រាប់បណ្តាញអ្នកសារព័ត៌មានកាលពីពេលថ្មីៗនេះថា-អាជ្ញាធរកម្ពុជាបានបញ្ជូនលោកទឹម-សាខន ទៅប្រទេសវៀតណាមតាមការស្នើសុំរបស់ព្រះអង្គ ដោយមានលិខិតជាលាយល័ក្ខណ៍អក្សរត្រឹមត្រូវ។ ដោយឡែកកាលពីព្រឹកថ្ងៃទី២ ខែសីហាឆ្នាំ២០០៧ គណៈកម្មការទី៤នៃរដ្ឋសភាបានស្នើឱ្យក្រសួងមហាផ្ទៃបន្តធ្វើការស្រាវជ្រាវនិងបំភ្លឺទាក់ទងទៅនឹងករណីបាត់ខ្លួនលោកទឹម សាខនផងដែរ ។

ចំណែកឯមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាវិញ បានស្នើឱ្យមានការធានាពីរដ្ឋាភិបាលវៀតណាមថា លោកទឹម សាខន មានស្ថានភាពសុខភាពល្អប្រសើរ ហើយមានសុវត្ថិភាពនៅពេលអនាគត ។ ភស្តុតាងណាមួយអំពីការធ្វើទុក្ខបុកម្នេញទៅលើរូបលោកនឹងត្រូវចាត់ទុកជាការរំលោភបន្ថែមទៀតទៅលើសិទ្ធិមនុស្សរបស់លោក ហើយមជ្ឈមណ្ឌលសិទ្ធិមនុស្សនឹងចាត់ទុកថា នោះគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលវៀតណាម ។ល

ភន្លិភា